ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
======

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
======

**មាតុភូមិនិវត្តន៍របស់ពលរដ្ឋខ្មែរ៣នាក់ ពីប្រទេសម៉ាឡេស៊ី**

------------

ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី បានជួយដោះស្រាយបញ្ហា និងរៀបចំមាតុភូមិនិវត្តន៍របស់ពលរដ្ឋខ្មែរចំនួន**៣នាក់** ដូចខាងក្រោម៖

- ពលរដ្ឋខ្មែរឈ្មោះ ***ស.ធ*** អាយុ៣៤ឆ្នាំ មកពីស្រុកកណ្តៀង ខេត្តពោធិ៍សាត់ បាននាំភរិយា និងកូនចំនួន៥នាក់ រួមទាំងកូនស្រីឈ្មោះ ***ធ.ល.ស*** អាយុ២ឆ្នាំ ទៅធ្វើការខុសច្បាប់នៅរោងចក្រផលិតប្លាស្ទិក តាំងពីឆ្នាំ២០១២។

នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦ ស្ថានទូតបានទទួលដំណឹងពីមន្ទីរពេទ្យមួយនៅម៉ាឡេស៊ី ថា កុមារី ***ធ.ល.ស*** បានព្យាបាលជំងឺរយៈពេលពីរខែ និងត្រូវបង់ថវិកាចំនួន៤០.០០០រីងហ្គិត (ប្រហែល ១០.០០០ដុល្លារអាមេរិក) ប៉ុន្តែក្រុមគ្រួសារពុំមានលទ្ធភាពបង់គ្រប់ឡើយ។ ស្ថានទូតបានចាត់មន្ត្រីទៅសួរសុខទុក្ខ និងបានចរចាជាមួយមន្ទីរពេទ្យចំនួន៣លើក រហូតមន្ទីរពេទ្យបានយល់ព្រមបញ្ចុះតម្លៃឲ្យទាបបំផុត ចំនួនតែ៥.០០០រីងហ្គិត (ប្រមាណ១.០០០ដុល្លារអាមេរិក) ប៉ុណ្ណោះ។

ស្ថានទូតបាននាំពលរដ្ឋ ***ស.ធ*** និងកុមារី ***ធ.ល.ស*** ទៅស្នាក់នៅស្ថានទូតនៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦ ហើយបានធ្វើលិខិតធ្វើដំណើរជូន និងសម្របសម្រួលជាមួយការិយាល័យអន្តោប្រវេសន៍ម៉ាឡេស៊ី។

អ្នកទាំងពីរ បានមកដល់ព្រលានយន្តហោះអន្តរជាតិ**ភ្នំពេញ** នៅថ្ងៃទី**៣១** ខែ**ធ្នូ** ឆ្នាំ**២០១៦** វេលាម៉ោង**១៦:០០**នាទី តាមជើងយន្តហោះ AK534។

- ពលការិនីខ្មែរឈ្មោះ ***រ.ស.រ*** អាយុ៣៤ឆ្នាំ មកពីខេត្តកំពង់ធំ បានធ្វើដំណើរទៅម៉ាឡេស៊ីខុសច្បាប់ដោយខ្លួនឯង និងធ្វើការងារតាមផ្ទះ ពីខែមករា ឆ្នាំ២០១៥។

ពលការិនី ត្រូវបាននិយោជកបរទេសចាប់រំលោភនៅរដ្ឋ Perak ហើយបានរត់តាមផ្លូវ និងត្រូវបាននគរបាលរដ្ឋ Perak ជូនទៅស្ថានទូតនៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៦។ ស្ថានទូតបានស្នើអាជ្ញាធរម៉ាឡេស៊ីតាមចាប់ជនល្មើស ដើម្បីផ្តន្ទាទោសតាមច្បាប់។ ប៉ុន្តែអាជ្ញាធរម៉ាឡេស៊ី មិនអាចរកឃើញជនល្មើសទេ ដោយសារពលការិនីមិនចាំអាស័យដ្ឋានដែលនាងធ្លាប់ស្នាក់នៅឡើយ។ ពលការិនី បានសម្រេចស្នើសុំ

ស្ថានទូតជួយឲ្យបានត្រឡប់មកកម្ពុជាវិញ។ ស្ថានទូតបានសម្របសម្រួលជាមួយការិយាល័យអន្តោប្រវេសន៍ម៉ាឡេស៊ី និងឧបត្ថម្ភសំបុត្រយន្តហោះជូននាងផងដែរ។

ពលការិនី ***វ.ស.វ*** បានមកដល់ព្រលានយន្តហោះអន្តរជាតិ**ភ្នំពេញ** ថ្ងៃទី**២៩** ខែ**ធ្នូ** ឆ្នាំ**២០១៦** វេលាម៉ោង **០៧:៥០នាទីព្រឹក** តាមជើងយន្តហោះ AK536 ។

ក្នុងអំឡុងពេលរង់ចាំត្រឡប់មកកម្ពុជាវិញ ស្ថានទូតបានផ្តល់ការស្នាក់នៅ និងអាហារបរិភោគជូនដល់ពលរដ្ឋខ្មែរទាំង**៣នាក់**ផងដែរ។

ភ្នំពេញ, ថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០១៧

**ជុំ សុន្ទរី**

**អ្នកនាំពាក្យ**

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ